# ស្ថានទូតអូស្ត្រាលី ភ្នំពេញ

## សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២២

## ទស្សនកិច្ចទៅកាន់ប្រទេសកម្ពុជា ដើម្បីចូលរួមកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានលើកទី៥៤ និងកិច្ចប្រជុំពាក់ព័ន្ធនានា

សប្តាហ៍នេះ ខ្ញុំនឹងធ្វើដំណើរមកកាន់ប្រទេសកម្ពុជា ដើម្បីដឹកនាំគណៈប្រតិភូអូស្ត្រាលី ទៅចូលរួមកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានលើកទី៥៤ នៅខេត្តសៀមរាប។ កិច្ចប្រជុំនេះនឹងជាកិច្ចប្រជុំលើកដំបូង របស់រដ្ឋមន្ត្រីសេដ្ឋកិច្ច ចាប់តាំងពីមេដឹកនាំអាស៊ានបានយល់ព្រមលើ ភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយថ្មី ជាមួយអូស្ត្រាលីកាលពីខែតុលា ឆ្នាំ២០២១។

ខ្ញុំទន្ទឹងរង់ចាំធ្វើការជាមួយសមភាគីរបស់ខ្ញុំ ដើម្បីពន្លឿនការចរចា ដើម្បីធ្វើឱ្យប្រសើរឡើងនូវកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-នូវែលសេឡង់ (AANZFTA) ដែលជាសសរទ្រូងកណ្តាល នៃទំនាក់ទំនងពាណិជ្ជកម្ម និងវិនិយោគរបស់អូស្ត្រាលី ជាមួយបណ្តាប្រទេសនៅអាស៊ាន។ អាស៊ានគឺជាប្រទេសដៃគូពាណិជ្ជកម្មធំទីពីរ របស់អូស្ត្រាលី។

ខ្ញុំក៏នឹងចូលរួមកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីស្តីពីកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយក្នុងតំបន់ (RCEP) ផងដែរ។ RCEP ផ្តល់នូវវេទិកាមួយសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងបញ្ជូនសញ្ញាដ៏រឹងមាំនៃការគាំទ្រក្នុងតំបន់សម្រាប់សេរីភាវូបនីយកម្មពាណិជ្ជកម្ម និងបទបញ្ជាផ្អែកលើច្បាប់។ យើងស្វាគមន៍ការអនុម័តច្បាប់នាពេលថ្មីៗនេះ នៅក្នុងប្រទេសឥណ្ឌូនេស៊ី ដែលជាជំហានដ៏សំខាន់មួយឆ្ពោះទៅរកការផ្តល់សច្ចាប័ន។

នៅពេលដែលប្រទេស និងសហគមន៍របស់យើងបានងើបពីពីការរាតត្បាតនៃជំងឺកូវីដ-១៩ ខ្ញុំនឹងប្រើប្រាស់កិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចនៃកិច្ចប្រជុំកំពូលអាស៊ីបូព៌ា ដើម្បីបញ្ជាក់ពីការគាំទ្ររបស់អូស្ត្រាលីសម្រាប់តំបន់ដែលបើកចំហ មានបរិយាបន្ន និងមានភាពធន់។

អូស្ត្រាលីប្តេជ្ញាធ្វើការយ៉ាងជិតស្និទ្ធជាមួយអាស៊ាន ដើម្បីផ្តល់ធាតុពិត ក្រោមភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ និងកិច្ចព្រមព្រៀងពាណិជ្ជកម្មក្នុងតំបន់របស់យើង ដើម្បីជាប្រយោជន៍ដល់អូស្ត្រាលី អាស៊ាន និងតំបន់ឥណ្ឌូប៉ាស៊ីហ្វិកកាន់តែទូលំទូលាយ។

អូស្ត្រាលី និងកម្ពុជា មានទំនាក់ទំនងមិត្តភាពយូរអង្វែង និងកិច្ចសហប្រតិបត្តិការជាប្រវត្តិសាស្ត្រ ហើយឆ្នាំនេះជាខួបទី៧០ឆ្នាំ នៃទំនាក់ទំនងការទូតរបស់យើង។ ខ្ញុំសង្ឃឹមនឹងពង្រឹងទំនាក់ទំនងនេះថែមទៀត នៅពេលខ្ញុំជួបជាមួយសមភាគីរបស់ខ្ញុំនៅចុងសប្តាហ៍នេះ។

**ទំនាក់ទំនងព័ត៌មាន៖** Media.Cambodia@dfat.gov.au